ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧ ស.ស.រ

# សេចក្តីសំរេច

## ស្តីពីការបង្កើត និងអនុញ្ញាតឱ្យប្រើប្រាស់ត្រា របស់គណៈកម្មការសិក្សា និងរៀបចំសាងសង់អាគារទីស្តីការនាយករដ្ឋមន្ត្រី

---

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ១៨ សសរ. ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាលកម្ពុជា ។
- យោងសេចក្តីស្នើសុំរបស់ **សម្តេចចៅហ្វាវាំង** ប្រធានគណៈកម្មការសិក្សា និងរៀបចំសាងសង់អាគារទីស្តីការ នាយករដ្ឋមន្ត្រី ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៩ ។

### សម្រេច

**ប្រការ ១ :** បង្កើត និងអនុញ្ញាតឱ្យប្រើប្រាស់ត្រា របស់គណៈកម្មការសិក្សា និងរៀបចំសាងសង់អាគារទីស្តីការនាយករដ្ឋមន្ត្រី ។

**ប្រការ ២ :** ត្រារបស់គណៈកម្មការសិក្សា និងរៀបចំសាងសង់អាគារទីស្តីការនាយករដ្ឋមន្ត្រី មានគំរូនៅក្នុងឧបសម្ព័ន្ធ ភ្ជាប់មក ជាមួយនេះ ។

**ប្រការ ៣ :** ត្រារបស់គណៈកម្មការសិក្សា និងរៀបចំសាងសង់អាគារទីស្តីការនាយករដ្ឋមន្ត្រី នឹងត្រូវអស់សុពលភាព បន្ទាប់ពី ការសាងសង់អាគារទីស្តីការនាយករដ្ឋមន្ត្រី ចប់ជាស្ថាពរ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការសិក្សា និងរៀបចំសាងសង់អាគារទីស្តីការនាយករដ្ឋមន្ត្រី និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០[illegible] ខែ មេសា ឆ្នាំ ២០០៩

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## សេចក្តីសំរេចលេខៈ ៧៨ សសរ.ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០០៩

## របស់រាជរដ្ឋាភិបាលកម្ពុជា

## ស្តីពីការបង្កើត និងអនុញ្ញាតឱ្យប្រើប្រាស់ត្រារបស់គណៈកម្មការសិក្សា និងរៀបចំសាងសង់អាគារទីស្តីការនាយករដ្ឋមន្ត្រី




គំរូត្រារបស់គណៈកម្មការសិក្សា និងរៀបចំសាងសង់
អាគារទីស្តីការនាយករដ្ឋមន្ត្រី
មានវិជ្ជមាត្រ ៤០មម.